អរិយធម៌អតិច (Aztec Civilization)

ជនជាតិអតិចមានដើមកំណើតចេញពីកុលសម្ព័ន្ធ នៅភាគខាងជើងនៃប្រទេសម៉ិកស៊ិកូ និងបានបង្កើតជាអរិយធម៌នៅក្នុងតំបន់មេសូអាមេរិក។[១] តាមរយៈទេពកថារបស់ជនជាតិនេះបានលើកឡើងថា ពួកគេមានកំណើតមកពីតំបន់ដែលមានឈ្មោះថា អាហ្សាតឡង់ (Aztlán) ដែលអ្នកស្រាវជ្រាវយល់ថា តំបន់ទន្ទេ តិចកូកូ (Texcoco) នៃប្រទេសម៉ិកស៊ិកូបច្ចុប្បន្ន។[២] ចំពោះអរិយធម៌អតិច គឺកើតចេញពីសិល្បៈអរិយធម៌មួយផ្សេងទៀតដែលហៅថា អរិយធម៌តុលតិច (Toltec) ដែលជាមនុស្សមកតាំងទីរស់នៅក្នុងតំបន់ទន្ទេ Texcoco នៅពាក់កណ្តាល ស.វ.ទី១០នៃគ.ស. ពោលគឺមកតាំងទីរស់នៅមុននៃការមកដល់របស់ជនជាតិអតិច។[៣]

តេណូជេចិឡាន់ (Tenochtitlan) ត្រូវបានអ្នកស្រាវជ្រាវសន្និដ្ឋានថា ជារាជធានីនៃអាណាចក្រអតិច ដែលកសាងប្រហែលនៅពាក់កណ្តាលនៃស.វ.ទី១៤នៃគ.ស. ហើយរាជធានីនេះស្ថិតនៅក្នុងតំបន់ទន្ទេ Texcoco ដែលបច្ចុប្បន្នមានចម្ងាយប្រមាណ៥០គីឡូពីទីក្រុងម៉ិកស៊ិកូ។[៤]

ចំពោះប្រវត្តិ និងឈ្មោះនៃអាណាចក្រអតិច គេតែងតែហៅឈ្មោះផ្សេងថា អាណាចក្រ Triple Alliance[៥] ដែលជាអរិយធម៌មួយកកើតឡើងនៅស.វ.ទី១៥នៃគ.ស.[៦] និងស្ថិតនៅក្នុងចំណោមបណ្តាអរិយធម៌មេសូអារិក(រូបលេខ១)។ អាណាចក្រ Triple Alliance គឺសំដៅលើ រដ្ឋសម្ព័ន្ធមិត្តបី ដែលរួមមានរដ្ឋ Texcoco , Tlacopan និង Tenochtitlan ហើយ អាណាចក្រ Triple Alliance នេះ គឺកើតឡើងពីការធ្វើសង្ត្រាមរវាងរដ្ឋ Texcoco , Tlacopan និង Tenochtitlan និងនៅក្នុងឆ្នាំ១៤២៨ រដ្ឋទាំងបីបានរួមបញ្ចូលគ្នា ហើយបន្តក្វាយជាអាណាចក្រអតិចដែល

---

[១] Tenochtitlan | History, Population, Significance, & Facts | Britannica

[២] https://www.history.com/news/aztec-empire-triple-alliance

[៣] https://www.worldhistory.org/

[៤] https://www.nationalgeographic.org/encyclopedia/tenochtitlan/

[៥] https://www.thoughtco.com/aztec-triple-alliance-170036

[៦] Aztec Civilization | National Geographic Society

មានរាជធានីគោលនៅ Tenochtitlan (រូបលេខ២)។[៧]

ការរៀបចំក្រុងនៃអារិយធម៌អាតិច ក៏មិនខុសអ្វីពីអារិយធម៌ម៉ាយ៉ាដែរ គឺជាការរៀបចំជាបណ្តុំនៃសំណង់ផ្សេងៗ ដែលមានសំណង់គោលនោះ គឺជាប្រាសាទថ្នាក់ៗមានរាងដូចពីរ៉ាមីត សម្រាប់ការគោរពដល់ព្រះក្នុងអារិយធម៌អាតិចបុរាណ ដែលជឿលើទំនៀមនៃការបូជាយញ្ញ (Time and place of sacrifice)។

រាជធានី Tenochtitlan ភាសាអង់គ្លេសហៅថា Metropolis ដែលមានសំណង់ប្រាសាទជាច្រើន ក្នុងនោះមានប្រាសាទសំខាន់ចំនួនពីរ មួយគឺប្រាសាទ Quetzalcoatl (រូបលេខ៣-៤) និងមួយទៀតគឺប្រាសាទពីរ៉ាមីតព្រះអាទិត្យ និងព្រះច័ន្ទ (Pyramid of Sun and Moon) (រូបលេខ៥-៦) ដែលអ្នកស្រាវជ្រាវយល់ថា ទីក្រុងនេះប្រៀបបានដូចនឹងស្ថានព្រះ (The place where the gods were created)។[៨] ចំពោះពាក្យ Quetzalcoatl ក្នុងអារិយធម៌អាតិចគឺមានន័យថាជាស្តេចនៃសត្វពស់ ដូចនៅនឹងប្រាសាទ Quetzalcoatl (The Pyramid of the Feathered Serpent) ដែលឃើញមានចម្លាក់សត្វពស់នៅជុំវិញប្រាសាទ(រូបលេខ៣)។ រីឯប្រាសាទពីរ៉ាមីតព្រះអាទិត្យ និងព្រះច័ន្ទ(Pryamid of Sun and Moon) គឺជាប្រាសាទពីរ៉ាមីតដែលមានកំពស់ខ្ពស់ជាងគេនៅក្នុងតំបន់មេសូអាមេរិក ពេលមានកំពស់ប្រមាណ៦៦ម៉ែត្រ។[៩]

អ្នកស្រាវជ្រាវបានរកឃើញរូបចម្លាក់ជាច្រើន ដោយគេបានដឹងថាបច្ចេកទេសនៃការធ្វាក់រូបនោះ គឺឃើញមានការប្រើប្រាស់នៅក្នុងអារិយធម៌ អូលមេក, ម៉យ៉ា និងអាតិចនេះ ដែលសុទ្ធសឹងជាអារិយធម៌ក្នុងតំបន់មេសូអាមេរិកដូចគ្នា[១០] លើសពីនេះតាមរយៈសំណង់សិល្ប: និងស្ថាបត្យកម្ម អ្នកស្រាវជ្រាវបានដឹងថា ប្រជាជនអាតិចមានចំណេះដឹងខាងផ្នែក

[៧] https://www.thoughtco.com/aztec-triple-alliance-170036

[៨] https://whc.unesco.org/en/list/414/

[៩] https://www.britannica.com/place/Pyramid-of-the-Sun

[១០] https://www.worldhistory.org/Aztec_Art/

គណិតវិទ្យា តារាសាស្ត្រ ប្រតិទិន និងការរៀបចំក្រុង ដែលដូចស្រដៀងនឹងអារ្យធម៌ម៉ាយ៉ា (រូបលេខ៦-៨)។

អាណាចក្រអាតិចត្រូវបានដួលរលំនៅដើមស.វ.ទី១៦ ពីសំណាក់ជនជាតិអេស្ប៉ាញ ដែលបានទៅដល់ក្នុងតំបន់មេសូអាមរិក និងបានធ្វើការឈ្លានទឹកដីនៃអាណាចក្រអាតិច។ ការឈ្លានពាននោះគឺ ដឹកនាំដោយ អ៊ែរណាន់ កដេស (Hernán Cortés) ហើយនិងបានធ្វើការគ្រប់គ្រងលើតំបន់រាជធានី Tenochtitlan។[១១]

តាមរយៈការសិក្សាលើកស្តុតាងដែលបានរកឃើញទាំងឡាយ ដោយអ្នកស្រាវជ្រាវ បានបង្ហាញអារ្យធម៌អាតិចមានកកើតឡើងដំបូងនៅស.វ.ទី១៣ និងបន្តក្លាយជាអាណាចក្រអាតិចដែលមានឥទ្ធិពលខ្លាំងក្លានៅក្នុងតំបន់មេសូអាមេរិក ឬអាមេរិកកណ្តាលនៅអំឡុងស.វ.ទី១៥ និង ដើមស.វ.ទី១៦ ហើយបញ្ចប់វិញនៅពាក់កណ្តាលស.វ.ទី១៦។

រូបលេខ១១៖ ផែនទីនៃអាណាចក្រអាតិចក្នុងឆ្នាំ ១៥១៩

ប្រភព៖ Wikimedia Commons

[១១] https://www.history.com/news/aztec-empire-fall-new-discovery

រូបលេខ២៤ៈ ទីក្រុង Teotihuacán

ប្រភពៈ Top Santé

រូបលេខ៣ៈ ប្រាសាទ Quetzalcoatl

ប្រភពៈ Khanacadamy

រូបលេខ៦៤ៈ ប្រាសាទ Quetzalcoatl

ប្រភពៈ Khanacadamy

រូបលេខ៥៤ៈ ប្រាសាទ ព្រះអាទិត្យ ព្រះច័ន្ទ

ប្រភពៈ Khanacadamy

រូបលេខ៦៖ ប្រាសាទ ព្រះអាទិត្យ ព្រះច័ន្ទ

ប្រភព៖ Unesco

រូបលេខ៦៖ រូបចម្លាក់ក្នុងសិល្ប:អតិច

ប្រភព៖ metmuseum.org

រូបលេខ៧៖ រូបចម្លាក់ក្នុងសិល្ប:អតិច

ប្រភព៖ metmuseum.org

រូបលេខ៨៖ អ្នកស្រាវជ្រាវយល់ថាជាទម្រង់នៃប្រតិទិន

ប្រភព៖ metmuseum.org

អត្ថបទដោយ៖ អេង គុណា